ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
លេខៈ ៨០/១៨ ក.ស.វ.

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតខុទ្ទកាល័យរបស់ឯកឧត្តម ឃឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៥០ សសរ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សម្រេច

**ប្រការ១.**

ត្រូវបានបង្កើតខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ហោខ ពិដ្ឋា** នាយកខុទ្ទកាល័យ
២- ឯកឧត្តម **សំ សំណាង** នាយករងខុទ្ទកាល័យ
៣- លោក **អ៊ុន តុលា** ទីប្រឹក្សាបច្ចេកទេស



Office of the Council of Ministers
Economic, Social and Cultural Council (ECOSOCC)
Address: #41, Russian Federation Blvd.
ទូរស័ព្ទ/ទូរសារ : (៨៥៥)-២៣ ២១ ១៩ ៤៣ , Tel/Fax : (855)-23 21 19 43

៤- លោក **មុត ភក្ដដា** ជំនួយការ

៥- លោក **នូ ពេជ្រខុនម៉េង** លេខាធិការ

**ប្រការ២**.-

គួនាទីភារៈកិច្ចរបស់ខុទ្ទកាល័យ មានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន។

**ប្រការ៣**..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤**..

អនុប្រធាននិងសមាជិកនៃក.ស.វ. អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក អនុប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋានក.ស.វ. និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ថ្ងៃ ៗ២១៤កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*

*រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១៨*

**ទេសរដ្ឋមន្ត្រី**

**ទទួលបន្ទុកបេសកកម្មពិសេស**

**យឹម ឈាយលី**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

- យោងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន

**តារាង**
**ស្តីពី**
**ការកំណត់កម្រិតមុខតំណែង ឈ្មោះមន្ត្រី មុខតំណែង ចំនួនមន្ត្រី និងប្រាក់បំណាច់ប្រចាំខែ**
**នៃមន្ត្រីខុទ្ទកាល័យទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

| ល.រ | កម្រិតមុខតំណែង | គោត្តនាមនិងនាម | មុខតំណែង | ចំនួនមន្ត្រីក្នុងមុខតំណែង(នាក់) | ប្រាក់បំណាច់ប្រចាំខែ(រៀល) |
|---|---|---|---|---|---|
| ១ | កម្រិតទី១ | ឯកឧត្តម ហេង វិជ្ជា | នាយកខុទ្ទកាល័យ | ១ | ២.៨០០.០០០ |
| ២ | កម្រិតទី២ | ឯកឧត្តម សំ សំណាង | នាយករងខុទ្ទកាល័យ | ១ | ២.៥០០.០០០ |
| ៣ | កម្រិតទី៣ | លោក អ៊ិន តុលា | បេសកជន ទីប្រឹក្សាបច្ចេកទេសឬមុខតំណែងប្រហាក់ប្រហែល | ១ | ២.១០០.០០០ |
| ៤ | កម្រិតទី៤ | | អនុពន្ធសភា អនុពន្ធសារព័ត៌មានឬមុខតំណែងប្រហាក់ប្រហែល | ០ | ១.៥០០.០០០ |
| ៥ | កម្រិតទី៥ | លោក មុត កក្កដា | ជំនួយការឬ មុខតំណែងប្រហាក់ប្រហែល | ១ | ១.១០០.០០០ |
| ៦ | កម្រិតទី៦ | លោក នូ ពេជ្រខុងម៉េង | លេខាធិការឬ មុខតំណែងប្រហាក់ប្រហែល | ១ | ១.០០០.០០០ |
| សរុប | | | | ៥ | |

បានឃើញនិងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៨
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បានឃើញនិងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៨
រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

បានឃើញនិងឯកភាព
ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៨
ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

**យឹម ណុលឡា**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១៨
នាយកខុទ្ទកាល័យ

**ហេង វិជ្ជា**